**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

# អនុស្សរណៈនៃការយោគយល់
# រវាង តំណាងបុគ្គលិក សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ
# និង ក្រុមហ៊ុន សុខា អូតែល

អនុស្សរណៈនៃការយោគយល់នេះត្រូវបានធ្វើឡើងនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ រវាង ប្រធានផ្នែកនៃសណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ (ពីនេះតទៅហៅថា "តំណាងបុគ្គលិក") និង ក្រុមហ៊ុន សុខា អូតែល (ពីនេះតទៅហៅថា "និយោជក")។

ដោយសារតែការផ្ទុះឡើងនូវជំងឺកូវីត ១៩ ដែលកំពុងតែឆ្លងរាលដាលយ៉ាងខ្លាំង នៅទូទាំងពិភពលោកនាពេលនេះ បានធ្វើឲ្យអាជីវកម្មសណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ ជួបប្រទះនូវការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរបំផុត។ ហេតុនេះ ដើម្បីសម្រាលនូវបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរនៅចំពោះមុខនេះ និយោជក និងតំណាងបុគ្គលិក បានចរចានិងព្រមព្រៀងគ្នាដាក់ឲ្យបុគ្គលិកមួយភាគធំឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

**ភាគីទាំងពីរបានព្រមព្រៀងគ្នា លើលក្ខខណ្ឌដូចខាងក្រោម៖**

- និយោជិតដែលត្រូវបានដាក់ឲ្យឈប់សម្រាកពីការងាររយៈពេលពីរ (២) ខែ នឹងមិនទទួលបានប្រាក់ឈ្នួល និងប្រាក់ជានានុគ្រោះទេ នៅក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។
- អតីតភាពការងាររបស់និយោជិតដែលដាក់ឲ្យឈប់សម្រាកដោយឥតប្រាក់ឈ្នួល នឹងមិនត្រូវបានប៉ះពាល់ឡើយ។
- ដើម្បីសម្រួលដល់ជីវភាពនិយោជិត នៅក្នុងអំឡុងពេលនៃការឈប់សម្រាកពីការងារដោយឥតប្រាក់ឈ្នួល រយៈពេលពីរ (២) ខែនេះ និយោជកបានសម្រេចដកប្រាក់មូលនិធិជំនួយបន្ទាន់ស្មើរតែ ១០០% មកបែងចែកជូននិយោជិតសណ្ឋាគារទាំងអស់ ដែលមានចំនួនសរុប ៦៣៦ នាក់ ដែលជាមធ្យមនិយោជិតម្នាក់ៗទទួលបានប្រាក់មូលនិធិជំនួយបន្ទាន់នេះចំនួន ២៨២ ដុល្លារអាមេរិក ។

ចំពោះនិយោជិតដែលត្រូវរក្សាទុកក្នុងចំនួនអប្បបរមា ទៅតាមតម្រូវការជាក់ស្តែងនៃផ្នែកនីមួយៗ សម្រាប់ធ្វើការពេញម៉ោង (៤ សប្តាហ៍ ក្នុងមួយខែ)៖

- និយោជិតធម្មតានឹងទទួលបានប្រាក់ឈ្នួល និងប្រាក់ជានានុគ្រោះ ១០០% ។
- និយោជិតថ្នាក់ប្រធាន/អនុប្រធានផ្នែក នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល និងប្រាក់ជានានុគ្រោះ ១០០% ព្រមទាំងប្រាក់ឧបត្ថម្ភបន្ថែមចំនួន ៥.០០ ដុល្លារអាមេរិក សម្រាប់ ១ ថ្ងៃធ្វើការ។

រីឯ និយោជិត ថ្នាក់ប្រធាន/អនុប្រធានផ្នែក ដែលតម្រូវឲ្យធ្វើការ ទៅតាមការងារតម្រូវ នឹងទទួលបានប្រាក់ឈ្នួល ៥០% នៃប្រាក់ខែគោល និងប្រាក់ធានានុគ្រោះ ដោយគណនាទៅតាមចំនួនថ្ងៃធ្វើការជាក់ស្តែងរបស់និយោជិតនីមួយៗ។ ក្រៅពីនេះនិយោជកនឹងឧបត្ថមបន្ថែមចំនួន ៥.០០ ដុល្លារអាមេរិក សម្រាប់ ១ ថ្ងៃធ្វើការ។

សូមបញ្ជាក់ថា ចំណុចដូចដែលបានរៀបរាប់ខាងលើនេះ គឺសម្រាប់ការអនុវត្តរយៈពេលពីរ (២) ខែ គិតចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹងជាថ្មី ប្រសិនបើស្ថានការណ៍មានការប្រែប្រួល ហើយគូភាគីនឹងពិនិត្យមើលអនុស្សរណៈនៃការយោគយល់នេះឡើងវិញ។

ដើម្បីជាសក្ខីភាពនៃការព្រមព្រៀង គូភាគីបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់នេះ ពីខាងក្រោមនេះ៖

**ហត្ថលេខាភាគីតំណាងនិយោជក**

ក្រុមហ៊ុន សុខា អូតែល SOKHA HOTEL CO., LTD. KINGDOM OF CAMBODIA

សុខ_ចន្ថា

**ហត្ថលេខាភាគីតំណាងនិយោជិត**

យ៉ូ ឡាន់ ហ៊ួ ____

ផ្លុង ច័ន្ទដារិទ្ធ ____

សុខ សូវុឌ្ឍី ____

វីលៀម ចុហ្គាណាថាន ____

ហ៊ូ កក់ ហៃ ____

យ៉ាន សារុធ ____

រស់ ង៉ែត ____

ម៉េង ស្រីលក្ខណ៍ ____

ភី វន្ថា ____